00417955

ការ/ND D288

**នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 22 / 10 / 2009
ម៉ោង (Time/Heure) : 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA Fuy

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស

ដាក់ទៅ: សហចៅក្រមស៊ើបអង្កេត

ថ្ងៃដាក់: ថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៩

ភាគីអ្នកដាក់: សហព្រះរាជអាជ្ញា

ភាសាដើម: អង់គ្លេស

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 23 / 12 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ **សាធារណៈ**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត**

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ**

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញា សុំដាក់ឯកសារនានាដែលមាននៅក្នុងសំណុំរឿងលេខ ០០១ បញ្ចូលនៅក្នុងសំណុំរឿងលេខ ០០២**

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** |
|---|---|
| សហព្រះរាជអាជ្ញា៖ | សហចៅក្រមស៊ើបអង្កេត៖ |
| លោកស្រី ជា លាង | ចៅក្រម យូ ប៊ុនឡេង |
| លោក William SMITH | ចៅក្រម Marcel LEMONDE |
| លោក យ៉េត ចរិយា | |
| លោក ពេជ្រ សម្បត្តិ | |
| លោក Tarik ABDULHAK | |

00417956

ឯកសារ: D288

**មេធាវីជនត្រូវចោទ:**

**នួន ជា**
លោក សុន អារុណ
លោក Michel PESTMAN
លោក Victor KOPPE

**អៀង សារី**
លោក អាង ឧត្តម
លោក Michael G.KARNAVAS

**អៀង ធីរិទ្ធ**
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS

**ខៀវ សំផន**
លោក សរ សូវ៉ាន
លោក Jacques VERGES

**កាំង ហ្គេកអ៊ាវ ហៅ ឌុច**
លោក ការ សាវុត្ថ
លោក François ROUX

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី:**

លោក គីម ម៉េងឃី
កញ្ញា ម៉ុច សុវណ្ណារី
លោកស្រី Martine JACQUIN
លោក Philippe CANNONE
លោកស្រី Elizabeth RABESSANDRATANA
លោកស្រី Annie DELAHAIE
លោកស្រី Fabienne TRUSSES-NAPROUS
លោក នី ចាន់ឌី
លោក ឡូ ជុនធី
កញ្ញា SILKE Studzinsky
លោក គង់ ពិសី
លោក ហុង គឹមសួន
លោក យុង ផានិត
លោក Pierre-Olivier SUR
លោកស្រី ស៊ីន សុវ៉ន
លោក Mahdev MOHAN
លោកស្រី NGUYEN Lyma
កញ្ញា Marie GUIRAUD
លោក Patrick BAUDOUIN
លោក Olivier BAHOUGNE
លោក David BLACKMAN

## ១. សេចក្ដីផ្ដើម

១. អនុលោមតាមវិធាន៥៥.១០ នៃវិធានផ្ទៃក្នុងសម្រាប់ អវតក សហព្រះរាជអាជ្ញា ស្នើឲ្យសហចៅក្រមស៊ើបអង្កេត ដាក់បញ្ចូលទៅក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (សំណុំរឿងលេខ ០០២) នូវច្បាប់ចម្លងនៃឯកសារសំខាន់ទាំងអស់ ដែលមាននៅក្នុងសំណុំរឿងលេខ០០១/១៨-០៧-២០០៧-អវតក/អជសរ (សំណុំរឿង លេខ ០០១) ដែលមិនទាន់បានផ្ទេរបញ្ចូលទៅក្នុងសំណុំរឿងលេខ ០០២ នៅឡើយ ។

## ២. សេចក្ដីពិចារណាដែលពាក់ព័ន្ធ

២. តាមកំណត់សំគាល់មួយ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨[1] សហចៅក្រមស៊ើបអង្កេត បាន សម្រេចថា ច្បាប់ចម្លងឯកសារនៃសំណុំរឿងលេខ ០០១ ដូចខាងក្រោមនេះ ត្រូវដាក់ បញ្ចូលនៅក្នុងសំណុំរឿងលេខ ០០២ ៖

ក. ឯកសារសំខាន់ទាំងអស់ ដូចមានរាយឈ្មោះនៅក្នុងអនុឬលដ៍រ (Sub-folder) ក្រោមជំពូក “D” ដែលមិនទាន់បានដាក់បញ្ចូលនៅក្នុងសំណុំរឿងលេខ ០០២ ពីមុនមកនៅឡើយ លើកលែងតែឯកសារដែលស្ថិតនៅក្រោមជំពូកលេខ D25 ចេញ (ពាក្យសុំតាំងខ្លួនជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីនានា ដែលទាក់ទងតែជា មួយនឹងសំណុំរឿងលេខ ០០១ ប៉ុណ្ណោះ) ហើយនិងជំពូកលេខ D98 ។ និង

ខ. របាយការណ៍ចិត្តសាស្ត្រស្ដីពី កាំង ហ្គេកអ៊ាវ ។

៣. នៅក្នុងកំណត់សំគាល់របស់ខ្លួន សហចៅក្រមស៊ើបអង្កេត បានថ្លែងថា ឯកសារដូចបាន ពោលខាងលើទាំងនេះ គឺអាចឲ្យបញ្ជាក់ពីការពិត នៅក្នុងសំណុំរឿងលេខ ០០២ បាន ។ សហព្រះរាជអាជ្ញា សន្និដ្ឋានថា ត្រូវតែអនុវត្តដូចគ្នានេះដែរ ចំពោះឯកសារសំខាន់ៗទាំងអស់ ដែលបានដាក់នៅក្នុងអម្លុងពេលនៃដំណាក់កាលជាបន្តបន្ទាប់មកទៀតនៃសំណុំរឿង លេខ ០០១ គឺនៅក្នុងពេលដំណើរការនីតិវិធីនៃសវនាការ ។

---

[1] កំណត់សំគាល់របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨, D108 ។

៤. សហព្រះរាជអាជ្ញា យល់ថា ការបញ្ជូនដែលខ្លួនកំពុងស្នើសុំនេះ អាចមានការប៉ះពាល់ដោយមកពីការដាក់បញ្ចូលទៅក្នុងសំណុំរឿងលេខ០០២ នូវច្បាប់ចម្លងនៃឯកសារទាំងអស់ដែលមាននៅក្នុងអនុហ្វូលឌ័រ ជំពូក "E" ដែលនៅក្នុងសំណុំរឿងលេខ ០០១ ។ សហព្រះរាជអាជ្ញា ទុកឱ្យសហចៅក្រមស៊ើបអង្កេតជាអ្នកសំរេចទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួនស្តីពីការអនុវត្តន៍ជាក់ស្តែងក្នុងការបញ្ជូននេះ ។

៥. ការជាប់ទាក់ទងគ្នា និងតម្លៃជាភស្តុតាងនៃឯកសារសំខាន់ៗ និងកំណត់ហេតុសវនាការដែលមកពីសំណុំរឿងលេខ០០១ គឺជាក់ស្តែងនៅចំពោះមុខពួកគេ ។ នៅក្នុងពេលសវនាការជំនុំជម្រះក្តីលើសំណុំរឿងលេខ០០១ ជនជាប់ចោទ កាំង ហ្គេកអ៊ាវ និងសាក្សីព្រមទាំងដើមបណ្តឹងរដ្ឋប្បវេណីដែលមានចំនួនដ៏ច្រើនបានផ្តល់នូវភស្តុតាងទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលបានកើតមានឡើងនៅខាងក្នុង និងនៅជុំវិញមន្ទីរសន្តិសុខស-២១ ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី១[2] ដែលអនុលោមតាមសំណុំរឿងលេខ ០០២ ត្រូវបានបើកឡើង ដែលតម្រូវឱ្យមានកិច្ចស៊ើបសួរមួយអំពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់ជនសង្ស័យទាំងឡាយ (ដែលបច្ចុប្បន្នគឺជាជនត្រូវចោទ) ខៀវ សំផន, នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខ ឬជាប់ទាក់ទងនឹងមន្ទីរសន្តិសុខនានានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងនោះរួមទាំងមន្ទីរស-២១ផង។ តាមស្មារតីនៃអង្គហេតុនេះ ភស្តុតាងដែលបានបង្ហាញជូននៅក្នុងពេលសវនាការជំនុំជម្រះក្តីលើសំណុំរឿងលេខ០០១ គឺមានការជាប់ទាក់ទងគ្នាដោយផ្ទាល់ទៅនឹងសំណុំរឿងលេខ០០២ ។ កាំង ហ្គេកអ៊ាវ ក៏ជាជនត្រូវចោទមួយរូបនៅក្នុងសំណុំរឿងលេខ០០២នេះដែរ ។

៦. ការដាក់ឯកសារ, ភស្តុតាង និងកំណត់ហេតុផ្សេងៗដែលមាននៅក្នុងសំណុំរឿងលេខ០០១ ក្នុងការត្រៀមរៀបចំសម្រាប់ពេលសវនាការ និងនៅក្នុងពេលសវនាការជំនុំជម្រះក្តី គឺជាកំណត់ហេតុជាផ្លូវការរបស់តុលាការ ដែលទទួលបានមកដោយស្របទៅតាមការធានាអះអាងនៃនីតិវិធីទាំងអស់ជាធរមាន អាស្រ័យហេតុនេះ យថាភូតនៃនីតិវិធីទាំងនេះក៏មិនបាច់មានការចោទសួរដែរ ។

---

[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧, D3 ។

៧. សហព្រះរាជអាជ្ញា ទទួលស្គាល់ថា កំណត់ហេតុសវនាការជំនុំជម្រះក្តីនានាដែលនៅក្នុងសំណុំរឿងលេខ០០១ ដែលរួមទាំង ឯកសារនានាក្នុងជំពូក "D" ផង ដែលប្រមូលបានក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរ គឺបានន័យថា ឯកសារដែលច្បាប់ចម្លងនៃឯកសារទាំងនោះត្រូវបានផ្ទេរចូលទៅក្នុងសំណុំរឿងលេខ០០២ អនុលោមតាមសេចក្តីសំរេចដែលបានលើកឡើងខាងលើ ។ បន្ទាប់ពីបានដាក់ និងពិនិត្យនៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូងមក ឯកសារទាំងនោះត្រូវបានគេដាក់លេខឲ្យមួយថ្មីទៀតគឺ លេខ "E3" ។ ដើម្បីឲ្យមានលក្ខណៈសាមញ្ញ មានភាពពេញលេញគ្រប់គ្រាន់ និងងាយស្រួលធ្វើការយោងនោះ សហព្រះរាជអាជ្ញា សូមស្នើយោបល់ថា គួរបានដាក់បញ្ចូលនូវច្បាប់ចម្លងនៃឯកសារទាំងនេះនៅក្នុងការផ្ទេរបញ្ជូននេះផង ។ ផ្ទុយទៅវិញ អង្គភាពទទួលបន្ទុកកំណត់ហេតុ និងបណ្ណសារនៃផ្នែកគ្រប់គ្រងតុលាការអាចមានលទ្ធភាពក្នុងការណែនាំអំពី ថាតើកំណត់ហេតុទាំងឡាយដែលក្នុងសំណុំរឿងលេខ០០២ គួរបានធ្វើបច្ចុប្បន្នភាពតាមរបៀបដូចម្តេច នៅពេលដែលកំណត់ហេតុទាំងនេះមានការទាក់ទងនឹងឯកសារទាំងនេះ ។

៨. ទីបញ្ចប់ ដូចដែលបានកត់សម្គាល់នៅក្នុងកថាខ័ណ្ឌទី២.កខាងលើ ការបង្គាប់ឲ្យផ្ទេរច្បាប់ចម្លងនៃឯកសារនៅក្នុងអនុហ្វូលឌ័រ (Sub-folder) ជំពូក "D" សហចៅក្រមស៊ើបអង្កេត បានឲ្យលើកលែងនូវពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលពាក់ព័ន្ធនឹងសំណុំរឿងលេខ ០០១ចេញ ។ ដើម្បីឲ្យមានការពេញលេញគ្រប់គ្រាន់ និងដោយហេតុថា ពុំមានការបង្គាប់ឲ្យមាននីតិវិធានការការពារណាមួយពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងលេខ០០១ទេនោះ សហព្រះរាជអាជ្ញា ស្នើថាឥឡូវនេះគឺជាពេលសមស្របក្នុងការដាក់ច្បាប់ចម្លងនៃពាក្យសុំទាំងអស់នោះ (គឺអនុហ្វូលឌ័រ (Sub-folder) ជំពូក D25 និង E2[3] នៅក្នុងសំណុំរឿងលេខ ០០១) ចូលទៅ ក្នុងសំណុំរឿងលេខ០០២ ។ ឯកសារផ្សេងៗដែលត្រូវបានដាក់ដើម្បីគាំទ្រដល់ពាក្យសុំ ទាំងនេះ អាចនឹងមានប្រយោជន៍ដល់ការបញ្ជាក់ការពិតបាន នៅក្នុងសំណុំរឿងលេខ ០០២ ។

[3] នៅក្នុងអនុហ្វូលឌ័រ E2 គឺមានពាក្យសុំទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿងលេខ ០០១ ។

## ៣. សំណើ

៩. សហព្រះរាជអាជ្ញា ស្នើឱ្យសហចៅក្រមស៊ើបអង្កេត ដោយមានការយល់ព្រមពី អង្គជំនុំជម្រះសាលាដំបូងផង សូមឱ្យចេញដីកាបង្គាប់ឱ្យធ្វើការផ្ទេរចូលទៅក្នុងសំណុំរឿងលេខ ០០២ នូវច្បាប់ចម្លងនៃឯកសារនានាពីក្នុងសំណុំរឿងលេខ ០០១ ដូចតទៅនេះ៖

ក. ឯកសារសំខាន់ៗ (ដែលរួមមាន កំណត់ហេតុ, ឯកសារដែលបានដាក់, ភស្តុតាង និងប្រតិចារិកនានាដែលបានចាត់ថាជាឯកសារសម្ងាត់ ឬជាសាធារណៈ) ដែលបានដាក់នៅក្នុងសំណុំរឿងលេខ ០០១ ចាប់តាំងពីពេលផ្ទេរសំណុំរឿងជូនទៅអង្គជំនុំជម្រះសាលាដំបូងមក, គឺថាជាអនុហ្វូលឌ័រក្នុងជំពូក "E" ទាំងមូល ព្រមទាំងឯកសារផ្សេងៗទៀត ដែលសហចៅក្រមស៊ើបអង្កេត យល់ឃើញថាមានការពាក់ព័ន្ធ, និង

ខ. ឯកសារទាំងអស់ដែលមាននៅក្នុង អនុហ្វូលឌ័រក្នុងជំពូក "D25" ។

១០. សហព្រះរាជអាជ្ញា នឹងត្រៀមអនុវត្តតាមសហចៅក្រមស៊ើបអង្កេត បើសហចៅក្រមស៊ើបអង្កេត យល់ឃើញថា សហព្រះរាជអាជ្ញាគួរធ្វើ សំណើមួយដាក់ជូនទៅអង្គជំនុំជម្រះសាលាដំបូង ស្តីពីការផ្ទេរឯកសារខាងលើនេះ ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៩ | **លោក យ៉ែត ចរិយា**<br>**សហព្រះរាជអាជ្ញារង** | ភ្នំពេញ | |
| | លោក William SMITH<br>**សហព្រះរាជអាជ្ញាស្តីទី** | ភ្នំពេញ | |